CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ធនាគារ ANZ Royal

# សន្ទនចក្ខុវិស័យប្រទេសកម្ពុជា*

ឆ្នាំ ២០០៩ លេខ ០១

## វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ដល់តំបន់យើង និងប្រទេសកម្ពុជា[១]

"វិបត្តិទូទាំងតំបន់ និង ពិភពលោកនេះ មិនមែនកើតចេញពីកម្ពុជាទេ ។ វិបត្តិនេះ កើតឡើងដោយកត្តាខាងក្រៅ ហួសពីការគ្រប់គ្រងរបស់កម្ពុជា ប៉ុន្តែ ជាវិបត្តិដែលជះឥទ្ធិពលមកដល់យើងទាំងអស់គ្នា ... យើងត្រូវធ្វើការរួមគ្នាដើម្បីឆ្លងឱ្យផុតពីវិបត្តិនេះ ធានារក្សាមិនឱ្យបាត់បង់ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ដែលកម្ពុជាសម្រេចបានក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក..."

*ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែន នៅក្នុងសុន្ទរកថាបើកសន្និសីទចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩*

### វិបត្តិ និង ពិភពលោកៈ ដើមកំណើត និង ផលប៉ះពាល់

វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល បានចាប់ផ្តើមនៅសហរដ្ឋអាមេរិក នៅពាក់កណ្តាលឆ្នាំ២០០៧ ហើយបានរីករាលដាលភ្លាមៗទៅកាន់ប្រទេសអភិវឌ្ឍន៍ឯទៀតៗ ។ នៅពេលវិបត្តិប្រែប្រួលកាន់តែធ្ងន់ធ្ងរឡើង ផលប៉ះពាល់មិនល្អបានជះទៅដល់ស្ទើរតែគ្រប់ប្រទេសនៅលើសាកលលោក ។ សូម្បីប្រទេសដែលពីដំបូង គេគិតថា អាចជំនះលើវិបត្តិនេះបាន ក៏ក្រោយមកត្រូវទទួលរងគ្រោះដែរ ។

មូលហេតុដើមនៃវិបត្តិ គឺការបាត់បង់ទំនុកចិត្តលើទីផ្សារអចលនទ្រព្យ... 

មូលហេតុដើមនៃវិបត្តិ គឺការបាត់បង់ទំនុកចិត្តលើទ្រព្យធ្វើអ៊ីប៉ូតែក និងការដួលរលំស្ថាប័នហិរញ្ញវត្ថុធំៗមួយចំនួន ជាបន្តមកទៀត ។ ព្រឹត្តិការណ៍ទាំងនេះ នាំឲ្យមានការថយចុះ ឥណទាន និងសាច់ប្រាក់ ដែលបានប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ។

កំណើនសេដ្ឋកិច្ចសាកល បានធ្លាក់ចុះយ៉ាងខ្លាំងដោយសារវិបត្តិ ហើយឆាប់ៗនោះ ប្រទេសមានសេដ្ឋកិច្ចជឿនលឿនភាគច្រើន ក៏ត្រូវជួបប្រទះនឹងការធ្លាក់ចុះសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ។ យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ផលិតផលពិភពលោក កើនបាន ៣,៤% នៅឆ្នាំ២០០៨ ធៀបនឹង ៥,២% នៅឆ្នាំ២០០៧ (ក្រាហ្វិក ១) ។ ទិន្នន័យប្រមូលបានសំរាប់ខែមករា ២០០៩ បង្ហាញថា ស្ថានការណ៍បានប្រែប្រួលកាន់តែអាក្រក់ឡើង ហើយគេប៉ាន់ស្មានថា នៅខែមករានេះ ផលិតផលពិភពលោកពីមួយឆ្នាំទៅមួយឆ្នាំ នឹងកើនត្រឹមតែ ១% ប៉ុណ្ណោះ ។

ទីផ្សារនៅតំបន់អាស៊ី ក៏មិនអាចគេចផុតពីវិបត្តិនេះដែរ ។ ផលិតផលរបស់បណ្តាបណ្តាប្រទេសអាស៊ាន មានកំណើនទាបជាងឆ្នាំមុនៗយ៉ាងច្រើន ។ ប្រទេសឧស្សាហកម្មថ្មីៗ (NIEs) ដែលមានកូរ៉េខាងត្បូង ហុងកុង និង តៃវ៉ាន់ ក៏ជួបស្ថានភាពនេះដែរ ប៉ុន្តែប្រទេសទាំងបី មានការធ្លាក់ចុះកំណើនគំហុកជាង ។ កំណើន ផសស ពិត របស់ប្រទេសចិន ក្នុងឆ្នាំ២០០៨ បានធ្លាក់ចុះអស់ ៤% ធៀបនឹងឆ្នាំ២០០៧ ហើយសេដ្ឋកិច្ចជប៉ុនបានរួមចុះ ដោយកំណើន ផសស បានធ្លាក់ពី ២,៤% នៅឆ្នាំ២០០៧ មកដល់ –០,៣% នៅឆ្នាំ២០០៨ ។

**ក្រាហ្វិក ១ : កំណើន ផសស ពិត (ជាភាគរយ)**




*ប្រភពៈ ព័ត៌មានថ្មីៗស្តីពីចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក (WEO) របស់ IMF នៅខែមករា ឆ្នាំ២០០៩*

១ អត្ថបទនេះ ជាការបូកសរុបបទបង្ហាញ និងការពិភាក្សាផ្សេងៗ នៅវគ្គទី១ នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។ វាគ្មិនក្នុងវគ្គនេះ មានដូចតទៅ: លោក John Nelmes តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំនៅកម្ពុជា, បណ្ឌិត Jayant Menon សេដ្ឋវិទូជាន់ខ្ពស់ នៃការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ នៃធនាគារអភិវឌ្ឍន៍អាស៊ី, ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង បណ្ឌិត Hossein Jalilian ប្រធានស្រាវជ្រាវនៃវិទ្យាស្ថាន វបសអ – CDRI ។

* ផ្អែកលើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ៈ ភាពជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal

ផលិតកម្មឧស្សាហកម្ម បានធ្លាក់ចុះយ៉ាងខ្លាំង ។ ទិន្នន័យបឋមបាន សំរាប់ខែមករា ២០០៩ បង្ហាញពីការធ្លាក់ចុះយ៉ាងខ្លាំង ធៀបនឹងខែដូចគ្នា ក្នុងឆ្នាំ២០០៨ ។ នៅប្រទេសចិន កំណើនផលិតកម្មឧស្សាហកម្មពីមួយឆ្នាំទៅមួយឆ្នាំ ធ្លាក់ចុះមកត្រឹម ១១,១% នៅខែមករា ២០០៨ និង ត្រឹម ៦,៤៣% នៅខែមករា ២០០៩ ។ នៅប្រទេសជប៉ុន អត្រាកំណើន ធ្លាក់ចុះគួរឲ្យតក់ស្លុតដល់ –២២,៥% នៅខែមករា ២០០៩ ធៀបនឹង អត្រាវិជ្ជមានដែលពិនិត្យឃើញនៅពាក់កណ្តាលឆ្នាំ២០០៨ ។

ទំនុកចិត្តរបស់អាជីវករ និងអ្នកប្រើប្រាស់ បានធ្លាក់ចុះយ៉ាងគំហុក ។ វិនិយោគិន មិនសូវចង់វិនិយោគ ហើយអ្នកប្រើប្រាស់ក៏មិនសូវចង់ចំណាយដែរ នៅចំពោះមុខហេតុការណ៍មិនប្រាកដប្រជា នៃសេដ្ឋកិច្ចជាតិ និងសាកល ដែលកំពុងបន្តទៅមុខ ។ វិនិយោគជាប់លាប់ បានធ្លាក់ចុះក្នុងតំបន់អាស៊ាន ហើយធ្លាក់ចុះកាន់តែខ្លាំងនៅតាមបណ្តាប្រទេសឧស្សាហកម្ម ។ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ចំណាយប្រើប្រាស់នៅតំបន់អាស៊ាន ហាក់ដូចមានស្ថិរភាព ប៉ុន្តែចំណាយប្រើប្រាស់នៅបណ្តាប្រទេសឧស្សាហកម្មថ្មី មានការថយចុះ ។

វិបត្តិនេះ បានធ្វើឲ្យការនាំចេញ និងនាំចូល ថយចុះ ។ នៅពាក់កណ្តាលឆ្នាំ២០០៨ ការនាំចូល និងនាំចេញទំនិញ នៃបណ្តាប្រទេសអាស៊ាន និងប្រទេសឧស្សាហកម្មថ្មី បានចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំង ។ កំណើនការនាំចេញនិងនាំចូលពីមួយឆ្នាំទៅមួយឆ្នាំរបស់ចិន ធ្លាក់ចុះពី ២៧% និង ៣៥% នៅពាក់កណ្តាលឆ្នាំ២០០៨ មកត្រឹម ៤,៣% និង –៩,០% នៅខែធ្នូ ២០០៨ ។ សំរាប់ជប៉ុនវិញ នៅចុងឆ្នាំ២០០៨ កំណើនទាំងពីរដូចខាងលើ បានធ្លាក់ចុះដល់ –៩,៩% និង ៦,១% ។

កំណើនខ្លាំងក្លានៃផលិតផល ត្រូវបានបញ្ចប់ ។ កាលពីមុននេះ ផលិតកម្មកសិកម្មបានទទួលផលចំណេញ ពីការឡើងថ្លៃម្ហូបអាហារខ្ពស់ផុសចេញពីវិបត្តិម្ហូបអាហារ និងថាមពល ។ ប៉ុន្តែការថយចុះតំរូវការក្នុងពិភពលោក ដែលបណ្តាលពីវិបត្តិបច្ចុប្បន្ន បានធ្វើឲ្យនិន្នាការឡើងថ្លៃ (អតិផរណា) ខាងលើនេះ ប្រែក្រឡាស់ទៅជា និន្នាការធ្លាក់ថ្លៃ (បរិត្តផរណា) វិញ ។ ថ្លៃទំនិញទាប បានបង្អាក់ទឹកចិត្តអ្នកផ្គត់ផ្គង់ និងបានបន្ទាបប្រាក់ចំណូលរបស់កសិករ ។

## វិបត្តិ និង ប្រទេសកម្ពុជា: ផលប៉ះពាល់ និង គោលនយោបាយឆ្លើយតប

កម្ពុជា បានជួបនឹងវិបត្តិចំពេលដែលខ្លួនកំពុងមានកំណើនសេដ្ឋកិច្ចខ្ពស់ មានការកាត់បន្ថយភាពក្រីក្រ និង មានស្ថិរភាពបរិយាកាសនយោបាយ ។ នៅអំឡុងឆ្នាំ១៩៩៤–២០០៧ ប្រទេសកម្ពុជា សំរេចបានអត្រាកំណើន ផសស ជាមធ្យមល្អវិសេសដល់ ១០% ដែលជួយកាត់បន្ថយភាពក្រីក្របាន ដល់ ១០% ក្នុងរយៈពេលដូចគ្នា ។ ការទទួលបានឡើងវិញនូវសន្តិភាព និង ស្ថិរភាព បន្ទាប់ពីមានសង្គ្រាមស៊ីវិល និងទំនាស់ផ្ទៃក្នុងខាងនយោបាយយូរឆ្នាំ បានជួយបំពេញលក្ខខណ្ឌដ៏ចាំបាច់សំរាប់ការងើបឡើងវិញនៃសេដ្ឋកិច្ច ។

ការលូតលាស់សេដ្ឋកិច្ចនៅកម្ពុជា ពឹងផ្អែកជាសំខាន់លើកំណើនក្នុងវិស័យឧស្សាហកម្មសំណង់ និងកាត់ដេរ និងវិស័យសេវាកម្មទេសចរណ៍ ។ តាំងពីដើមរៀងមក ការចូលរួមរបស់វិស័យកសិកម្មនៅក្នុងកំណើន មានលក្ខណៈមិនទៀងទាត់ទេ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗនេះវាមានអត្រាកំណើនជាមធ្យមល្អ ដល់ ៥% ។

វិបត្តិមិនបានជះឥទ្ធិពលដោយផ្ទាល់មកលើកម្ពុជាទេ ដោយហេតុថា ធនាគារកំពុងដំណើរការនៅក្នុងប្រទេសកម្ពុជា មានការពាក់ព័ន្ធតិចតួចទៅនឹងផលិតផលហិរញ្ញវត្ថុគ្រោះថ្នាក់ដែលបង្កវាឡើង ។ ប៉ុន្តែ ឥទ្ធិពល

ក្រាហ្វិក ២: កំណើន ផសស ពិត នៅកម្ពុជា (គិតជាភាគរយ)




ប្រភព: ទិន្នន័យរបស់ IMF

អវិជ្ជមានបានធ្លាក់មកលើកម្ពុជា តាមរយៈផលប៉ះពាល់ទៅលើវិស័យជំរុញកំណើនសំខាន់ៗ របស់ប្រទេស ។

វិបត្តិ បានឆាថៅបង្អាក់អត្រាកំណើនល្អវិសេសរបស់កម្ពុជា ។ តួលេខប៉ាន់ស្មាននៃកំណើន មានការប្រែប្រួលខុសគ្នា ដោយកំណើនផលិតផលបានធ្លាក់ចុះ ហើយវិស័យកាត់ដេរ សំណង់ និង ទេសចរណ៍នៅកម្ពុជា បានទទួលការប៉ះទង្គិចយ៉ាងខ្លាំង ។ ដោយឡែកវិស័យកសិកម្មឃើញមានភាពធន់ល្អជាងគេ ប៉ុន្តែការនាំចេញផលិតផលកសិកម្មមួយចំនួន ក៏ទទួលរងផលប៉ះពាល់ពីវិបត្តិនេះដែរ ។ យោងតាម IMF កំណើន ផសស នៅកម្ពុជា បានធ្លាក់ចុះពី ១០,២% នៅឆ្នាំ២០០៧ មកត្រឹមប្រហែល ៦% នៅឆ្នាំ២០០៨ ។

វិបត្តិនេះ បានធ្វើឲ្យការនាំចេញ និងនាំចូលរបស់កម្ពុជាថយចុះ ។ ទំនិញជាប់លាប់ ដូចជា រថយន្ត និង ទោចក្រយានយន្ត ជាដើម បានថយចុះតំរូវការប្រើប្រាស់ភ្លាមៗ ចាប់តាំងពីប្រហែលពាក់កណ្តាលឆ្នាំ ២០០៨ (ប៉ុន្តែក្នុងករណីនេះ វិបត្តិថាមពលក្នុងពេលកន្លងមក អាចជួយពន្យល់បានខ្លះពីការថយចុះនៃការលក់ទំនិញទាំងនេះ) ។ នៅពេលជាមួយគ្នា ទំនិញនាំចេញបានថយចុះយ៉ាងខ្លាំង ដោយជាចំបងមកពីការថយចុះតំរូវការក្នុងពិភពលោក ។ ការនាំចេញរបស់កម្ពុជា មានលក្ខណៈងាយរងគ្រោះណាស់ ដោយសារមានតិចមុខ ហើយក្នុងនោះ វិស័យកាត់ដេរតំណាងឲ្យដល់ទៅពីរភាគបីនៃការនាំចេញសរុប ។

កំណើនវិស័យកាត់ដេរនៅកម្ពុជា ទទួលរងឥទ្ធិពលធ្ងន់ធ្ងរពីវិបត្តិ ។ គេបានវាយតម្លៃថា អត្រាកំណើនក្នុងវិស័យនេះ បានធ្លាក់ចុះពីប្រហែល ៨% នៅឆ្នាំ២០០៧ មកដល់ ៣,៣% នៅឆ្នាំ២០០៨ ។ ការធ្លាក់ចុះនេះ បណ្តាលមកពីការថយចុះតំរូវការនៅសហរដ្ឋអាមេរិក (US) ដែលជាទីផ្សារនាំចេញសំខាន់បំផុតរបស់កម្ពុជា ។ សំលៀកបំពាក់នាំចេញពីកម្ពុជា ដើរស្របគ្នាខ្លាំងណាស់ជាមួយនឹងសកម្មភាពលក់រាយនៅ US ដែលរងនូវការធ្លាក់ចុះយ៉ាងខ្លាំង ។ រូបិយវត្ថុដែលឡើងថ្លៃ មិនបានជួយសំរួលស្ថានភាពនៅកម្ពុជាទេ ពីព្រោះវាបានធ្វើឲ្យទំនិញនាំចេញរបស់កម្ពុជាឡើងថ្លៃ ហើយថយចុះកំលាំងប្រកួតប្រជែង ។ ចាប់ពីខែតុលា ២០០៨ ដល់ មករា ២០០៩ កំណើនពីមួយឆ្នាំទៅមួយឆ្នាំ នៃបរិមាណនាំចេញសំលៀកបំពាក់ពីកម្ពុជា បានធ្លាក់ចុះយ៉ាងខ្លាំង ហើយ តំលៃនៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា បានធ្លាក់ចុះគួរឲ្យបារម្ភពីតួលេខមធ្យមប្រចាំខែ ២០០លានដុល្លារUS នៅឆ្នាំ២០០៨ មកត្រឹម ១៦៥លានដុល្លារUS នៅខែមករា និង ១០២លានដុល្លារUS នៅខែកុម្ភៈ ឆ្នាំ២០០៩ ។ ចំនួនរោងចក្រកាត់ដេរដែលកំពុងដំណើរការ ក៏បានថយចុះពី ២៩២ នៅចុងឆ្នាំ២០០៧ មកត្រឹម ២៨៨ នៅខែមករា ២០០៩ និង ២៧៧ នៅខែកុម្ភៈ ២០០៩ ។ ចំពោះកំលាំងពលកម្មវិញ នៅខែកញ្ញា ២០០៨ ចំនួនកម្មករកាត់ដេរកើន

ខ្ពស់បំផុតដល់ ៣៥២.០០០នាក់ ហើយក៏ធ្លាក់ចុះមកត្រឹម ៣០១.០០០នាក់វិញ នៅខែកុម្ភៈ ២០០៩ ដោយសារការបិទរោងចក្រ ឬ ការកាត់បន្ថយចំណាយប្រតិបត្តិការ ។

ផលិតផលកសិកម្មមួយចំនួនដែលជាទំនិញនាំចេញផ្តល់ចំណូលសំខាន់ៗរបស់កម្ពុជា ក៏ទទួលរងការប៉ះពាល់យ៉ាងខ្លាំងពី ការថយចុះតំរូវការក្នុងពិភពលោក និងការធ្លាក់ថ្លៃដែរ ។ ប៉ុន្តែតាមការពិនិត្យជារួម វិស័យកសិកម្មកម្ពុជា មានលទ្ធផលល្អនៅឆ្នាំ២០០៨ ។

វិស័យទេសចរណ៍ ក៏ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដែរ ។ ចំនួនភ្ញៀវទេសចរមកកម្ពុជាបានថយចុះ ចំណូលបានពីប្រាសាទអង្គរក៏ថយចុះ ហើយអត្រាស្នាក់នៅសណ្ឋាគារក៏ថយចុះដែរ ។ អតិផរណាខ្ពស់នៅ ឆ្នាំ២០០៨ និងប្រាក់រៀលឡើងថ្លៃខ្លាំងនាពេលបច្ចុប្បន្ន បានធ្វើឲ្យប្រទេសកម្ពុជាក្លាយជាគោលដៅទេសចរណ៍មានថ្លៃខ្ពស់ជាងមុន ។ តាមការប៉ាន់ស្មានជាច្រើន វិស័យទេសចរណ៍ដែលធ្លាប់តែមានកំណើនជាមធ្យមប្រហែល ២៥% បានធ្លាក់កំណើនមកត្រឹមប្រហែល ៩% ប៉ុណ្ណោះ នៅឆ្នាំ២០០៨ ។

វិបត្តិនេះក៏បានប៉ះពាល់យ៉ាងច្បាស់ ទៅលើវិស័យអចលនទ្រព្យ និងសំណង់ ។ នៅរាជធានីភ្នំពេញ គំរោងសាងសង់ធំៗមួយចំនួន បានពន្យារពេលបង្ហើយសំណង់ ដោយសារការថយចុះវិនិយោគផ្ទាល់ពីបរទេស *(FDI)* ។ តំលៃអនុមតិគំរោងសាងសង់ ដែលជាសូចនាករដ៏សំខាន់មួយបានថយចុះអស់ ៤០% នៅឆ្នាំ២០០៨ ។

*FDI* សំខាន់ខ្លាំងណាស់ចំពោះកម្ពុជា ។ ប្រហែលជិត ៦០% នៃវិនិយោគទាំងអស់នៅកម្ពុជា បានមកពី *FDI* ជាពិសេសវិស័យសំខាន់ៗដែលជំរុញកំណើនសេដ្ឋកិច្ចត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើហិរញ្ញវត្ថុបរទេសនេះ ។ រោងចក្រកាត់ដេរ ក្រុមហ៊ុនទេសចរណ៍ និងគំរោងសាងសង់ជាច្រើនទទួលបានហិរញ្ញវត្ថុពី *FDI* ។ ប៉ុន្តែគួរឲ្យស្តាយណាស់ដែល វិបត្តិបានធ្វើឲ្យពួកវិនិយោគិនក្នុងទូទាំងពិភពលោក កាត់បន្ថយ លុបចោល ឬពន្យារពេលគំរោងវិនិយោគរបស់ពួកគេ ដោយសារពិបាកនឹងរកបានឥណទាន ឬប្រភពទុនអ្វីផ្សេងមកប្រើការ ។ បញ្ហាដូចគ្នាក៏ចោទលើវិនិយោគិននៅកម្ពុជាដែរ ដែលបណ្តាលឲ្យវិនិយោគនៅក្នុងប្រទេសធ្លាក់ចុះ ។ វិនិយោគិនកូរ៉េខាងត្បូង ទទួលរងឥទ្ធិពលខ្លាំងជាពិសេស ពីព្រោះវិបត្តិបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើប្រទេសដើមរបស់ពួកគេ ។ ទោះយ៉ាងនេះក្តីមានការលើកឡើងថា វិនិយោគិនកូរ៉េ នៅតែមានទំនុកចិត្តលើសេដ្ឋកិច្ច ហើយគំរោងខ្នាតតូច និងខ្នាតមធ្យម នៅតែមានដំណើរការ ។

វិបត្តិបានបង្កើតបញ្ហាប្រឈមមួយចំនួនចំពោះប្រព័ន្ធធនាគារក្នុងស្រុក ទោះបីធនាគារនៅកម្ពុជាជាទូទៅ មានស្ថានភាពហិរញ្ញវត្ថុល្អ និងមិនសូវពាក់ព័ន្ធនឹងទ្រព្យសកម្មមិនល្អដែលធ្វើឲ្យវិបត្តិផ្ទុះឡើងនោះក្តី ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស ដែលជាមធ្យមមាន ៩៨% នៃប្រាក់បញ្ញើសរុបរបស់ធនាគារ កើនបានប្រហែលតែ ១% មកដល់ខែធ្នូ ២០០៨ ដែលបណ្តាលឲ្យមានការព្រួយបារម្ភពីធនបំរុងដែលធនាគារត្រូវរក្សាទុក ។ បញ្ហាព្រួយបារម្ភមួយផ្សេងទៀត គឺ ការពាក់ព័ន្ធរបស់ធនាគារនៅក្នុងផ្នែកអចលនទ្រព្យដែលមានហានិភ័យខ្ពស់ជាងមុនដោយសារតែវិបត្តិ និងការធ្លាក់ថ្លៃអចលនទ្រព្យ (ការរលំរលាយកំណើនលឿនៗនៃអចលនទ្រព្យ) ។ កំចីធនាគារសំរាប់ផ្នែកអចលនទ្រព្យ ក៏មានការរឹតបន្តឹង ហើយឥណទានសំរាប់វិស័យឯកជនទាំងមូលក៏ថយចុះ ។ បន្ទាប់ពីឡើងដល់កំរិតកំពូល ១០០% នៅខែឧសភា ២០០៨ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃឥណទានសំរាប់វិស័យឯកជនបានធ្លាក់ចុះប្រហែល ៤៥% នៅខែមករា ២០០៩ ។

ស្របតាមនិន្នាការសាកល ថ្លៃទំនិញផ្សេងៗនៅកម្ពុជាបានធ្លាក់ចុះ ទោះបីវានៅតែមានកំរិតខ្ពស់ បើធៀបនឹងកំរិតថ្លៃពីមុននោះក្តី ។ ការចុះថ្លៃនេះជាដំណឹងល្អសំរាប់អ្នកប្រើប្រាស់ ប៉ុន្តែវាបានចោទបញ្ហាដល់ពួកផលិតករ និងអ្នកនាំចេញ ។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ *(CPI)* បានធ្លាក់ចុះដល់ ១៣,៥% នៅក្នុងខែធ្នូ ២០០៨ ធៀបនឹង ២៥,៧% កាលពីខែឧសភាក្នុងឆ្នាំដដែល ។

វិបត្តិសាកលនេះ ទំនងធ្វើឲ្យស្ថានភាពជនក្រីក្រនៅកម្ពុជាកាន់តែយ៉ាប់យ៉ឺនថែមទៀត ដោយសារឥទ្ធិពលអាក្រក់ទៅលើភាពមានការងារធ្វើ និងប្រាក់ចំណូល ។ ជនក្រីក្រនៅតាមទីជនបទជាច្រើន ពឹងផ្អែកលើវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ សំរាប់ការចិញ្ចឹមជីវិត និងសំរាប់រកប្រាក់ផ្ញើត្រលប់ទៅផ្ទះ ។ អ្នកខ្លះទៀតពឹងលើប្រាក់ផ្ញើមកឲ្យដោយសមាជិកគ្រួសារឬសាច់ញាតិដែលចេញទៅធ្វើការនៅប្រទេសក្រៅ (ស្របច្បាប់ ឬខុសច្បាប់) ដូចជា ប្រទេសថៃជាដើម ។ គួរឲ្យស្តាយណាស់ វិបត្តិសាកល បានរុញច្រានឲ្យរោងចក្របិទទ្វារ កាត់បន្ថយប្រតិបត្តិការ ឬក៏ពន្យារពេលគ្រោងការណ៍ នៅគ្រប់ទីកន្លែង ។ បញ្ហាទាំងអស់នេះ នាំឲ្យមានការបាត់បង់ការងារ ឬកង្វះការងារធ្វើពេញលេញ ។

លើសពីនេះទៀត ប្រជាជនកម្ពុជាជាច្រើនដែលកន្លងមកអាចងើបពីភាពក្រីក្របានបន្តិចហើយ ទំនងត្រូវធ្លាក់ចូលទៅក្នុងស្ថានភាពពីមុនវិញ ដោយសារវិបត្តិបានកាត់បន្ថយប្រាក់ចំណូលរបស់ពួកគេ ។ គេរកឃើញថា សំរាប់ប្រជាជនកម្ពុជាមួយភាគធំ ការប្រែប្រួលប្រាក់ចំណូលតែត្រឹមប៉ុន្មានរយរៀលក្នុងមួយថ្ងៃ ក៏ប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពរស់រានរបស់ពួកគេដែរ ។

ដើម្បីឆ្លើយតបភ្លាមៗទៅនឹងឥទ្ធិពលនៃវិបត្តិ រដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធានការជាក់លាក់មួយចំនួន ដើម្បីជួយសង្គ្រោះវិស័យសេដ្ឋកិច្ចផ្សេងៗដែលរងការប៉ះទង្គិចខ្លាំង ។ វិធានការទាំងនេះរួមមានការលើកលែងពន្ធលើប្រាក់ចំណេញជាមុន ១% សំរាប់ផ្នែកកាត់ដេរ, ការកាត់បន្ថយធនបំរុងសំរាប់ធនាគារ ពី ១៦% មកត្រឹម ១២%, ការលុបចេញវិញនូវការដាក់កំរិតអតិបរមាត្រឹម ១៥% ទៅលើការផ្តល់កំចីដល់ផ្នែកអចលនទ្រព្យ, ផែនការធ្វើឲ្យសាមញ្ញនូវបែបបទលើការធ្វើដំណើរសំរាប់ភ្ញៀវទេសចរ, ផែនការបង្កើតមូលនិធិកសិកម្ម និង ការបង្កើតមូលនិធិជាតិសំរាប់សន្តិសុខសង្គម *(NSSF)* ។ រដ្ឋាភិបាលបានជំរុញឲ្យបញ្ឈប់គោលនយោបាយការពារផលិតផលក្នុងស្រុក ក្នុងអំឡុងពេលធ្លាក់ចុះសេដ្ឋកិច្ច និងបានសង្កត់ធ្ងន់ពីអត្ថប្រយោជន៍នៃសមាហរណកម្ម និងការបើកចំហពាណិជ្ជកម្ម ។ រដ្ឋាភិបាលក៏បានអំពាវនាវដល់អ្នកពាក់ព័ន្ធនានាក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ឲ្យចូលរួមធ្វើកំណែទំរង់ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពាណិជ្ជកម្ម ក៏ដូចជាសេដ្ឋកិច្ចទាំងមូល ។

## វិបត្តិ និង មធ្យោបាយឆ្ពោះទៅមុខៈ ចក្ខុវិស័យ និង ទិសដៅគោលនយោបាយទៅអនាគត

ចក្ខុវិស័យសំរាប់ឆ្នាំ២០០៩ មានភាពអាប់អួរ ហើយគេរំពឹងថា សេដ្ឋកិច្ចពិភពលោកនឹងធ្លាក់ចុះថែមទៀត ។ ដោយសារវិបត្តិកាន់តែធ្ងន់ធ្ងរ ហើយការនាំចេញកាន់តែធ្លាក់ចុះ ការគន់គូរពីកំណើនផលិតផល ក៏កាន់តែទុទិដ្ឋិនិយមខ្លាំងឡើង ។ ឧទាហរណ៍ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានប៉ាន់ស្មានពីដំបូងថា ផលិតផលពិភពលោកនៅឆ្នាំ២០០៩ មានកំណើន ២,២% ប៉ុន្តែក្រោយមក បានកែតួលេខប៉ាន់ស្មាននេះមកត្រឹម ០,៥% វិញ ដោយសារស្ថានភាពសេដ្ឋកិច្ចកាន់តែអាក្រក់ឡើង ។ គេរំពឹងថា សេដ្ឋកិច្ចពិភពលោក នឹងនៅតែទន់ខ្សោយរហូតដល់ឆ្នាំ២០១០ ។

សេដ្ឋកិច្ចកម្ពុជា នឹងធ្លាក់ចុះទៀតនៅក្នុងឆ្នាំនេះ ។ តួលេខប៉ាន់ស្មានចុងក្រោយរបស់ *IMF* បង្ហាញថា កំណើន ផសស នឹងធ្លាក់ចុះដល់ –០,៥% នៅឆ្នាំ២០០៩ ហើយរើបឡើងវិញយឺតៗនៅឆ្នាំ២០១០ ។ ភាពមិនប្រាកដ

ក្រាហ្វិក ៣ : ការគន់គូរពី កំណើន ផសស ពិត នៅឆ្នាំ២០០៩




ប្រភព : ពត៌មានថ្មីៗស្តីពីចក្ខុវិស័យសេដ្ឋកិច្ចពិភពលោក (WEO) របស់ IMF នៅខែមករា ឆ្នាំ២០០៩ ។ ការប៉ាន់ស្មានរបស់ IMF សំរាប់កម្ពុជា

ប្រជា និងហានិភ័យ នៅតែបន្តចោទបញ្ហាចំពោះសេដ្ឋកិច្ច ។

វិស័យកំណើនសំខាន់ៗរបស់កម្ពុជា នឹងបន្តរងឥទ្ធិពលពីភាពមិនអំណោយផលនៃបរិយាកាសខាងក្រៅ ។ ការនាំចេញសំលៀកបំពាក់ទំនងជាបន្តជួបការលំបាក ដោយសារតាមការគន់គូរ សកម្មភាពលក់រាយនៅសហរដ្ឋអាមេរិក នឹងធ្លាក់ចុះអស់ ១០% នៅឆ្នាំ២០០៩ ។ ដូចគ្នាដែរ វិស័យទេសចរណ៍រំពឹងថា នឹងធ្លាក់ចុះអស់ ០,៥% នៅឆ្នាំនេះ ។

ខាងផ្នែករឿងល្អ វិស័យកសិកម្មនៅកម្ពុជារំពឹងថា នឹងបន្តមានលទ្ធផលល្អក្នុងឆ្នាំនេះ ។ ប៉ុន្តែការចុះថ្លៃ ផលិតផលកសិកម្ម នឹងបន្តចោទបញ្ហាដល់ការនាំចេញទំនិញទាំងនេះ ។

ដើម្បីជួយឲ្យសេដ្ឋកិច្ចកម្ពុជា ជំនះលើឥទ្ធិពលវិបត្តិសាកល និងរើបឡើងវិញ រដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ត្រូវតែធ្វើសហប្រតិបត្តិការជាមួយគ្នា និងសំរបសំរួលសកម្មភាពរបស់ពួកគេ ។ វិធានការដាក់លាក់ និងការលះបង់មួយចំនួន គឺជាការចាំបាច់ ។ នៅពេលកំណែទំរង់ទទួលបានជោគជ័យ រដ្ឋាភិបាល និងដៃគូនានា ត្រូវតែបន្តកិច្ចប្រឹងប្រែងទៅមុខទៀត ។ ការបើកផ្តល់ប្រាក់ជំនួយបន្ទាន់សំរាប់ហេដ្ឋារចនាសម្ព័ន្ធ និងគ្រោងការណ៍ផ្សេងៗទៀត ក៏ជាការចាំបាច់ផងដែរ ។

កំណែទំរង់សារពើពន្ធ ដែលរដ្ឋាភិបាលបានធ្វើឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ បាននាំឲ្យចំណូលថវិកាកើនឡើងគួរឲ្យកត់សំគាល់ ។ ទោះយ៉ាងនេះក្តី រដ្ឋាភិបាលពុំមានលទ្ធភាពអ្វីច្រើនខាងពន្ធដារ ដើម្បីកសាងកញ្ចប់ជំរុញសេដ្ឋកិច្ចទេ ក្រៅតែពីការពង្រីកគំរោងថវិកាដែលបានគ្រោងឡើងសំរាប់ឆ្នាំនេះ ។ ចំពោះគោលនយោបាយរូបិយវត្ថុវិញ ដុល្លារូបនីយកម្មកំរិតខ្ពស់នៃសេដ្ឋកិច្ច បានកាត់បន្ថយប្រសិទ្ធភាពនៃ គោលនយោបាយនេះ ក្នុងការជួយទ្រទ្រង់សេដ្ឋកិច្ចទប់ទល់នឹងឥទ្ធិពលនៃវិបត្តិ ។

ឱនភាពថវិកាធំមួយ បានគ្រោងឡើងសំរាប់ឆ្នាំ២០០៩ ដើម្បីធ្វើជាគ្រឿងជំរុញសេដ្ឋកិច្ច ។ IMF រំពឹងថា ឱនភាពនេះ នឹងកើនដល់ ៤,៧៥% នៃ ផសស ។ ដើម្បីជំរុញសេដ្ឋកិច្ចឲ្យបានសក្តិសិទ្ធិ និងជួយជនងាយរងគ្រោះក្នុងការប្រឈមមុខនឹងវិបត្តិ រដ្ឋាភិបាលត្រូវការថវិកាបន្ថែមសំរាប់ចំណាយទៅលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសុវត្ថិភាពសង្គម (ឧ. ការផ្ទេរប្រាក់ឲ្យដោយផ្ទាល់ ឬស្បៀងពលកម្ម) ។ ម្យ៉ាងទៀត ការរីកចំរើនក្នុងការប្រមូលចំណូលថវិកា ក៏ត្រូវតែបន្តទៅមុខដែរ ។

ជំរើសគោលនយោបាយជាច្រើនអាចកសាងឡើង ដោយឈរលើមេរៀនសំខាន់ៗដែលទទួលបានពីវិបត្តិ ដូចជា តំរូវការប្តូរទិសដៅពាណិជ្ជកម្ម ដើម្បីបែកពង្រាយហានិភ័យជាដើម ។ ពាណិជ្ជកម្មក្នុងតំបន់ត្រូវតែពង្រីងឡើង ដើម្បីជួយសំរាលផលប៉ះពាល់នៃការវិវត្តន៍មិនអំណោយផលផ្សេងៗនៅក្នុង តំបន់ឯទៀតនៅលើសាកលលោក ។ សំរាប់វិស័យកាត់ដេរ គឺត្រូវធ្វើពិពិធកម្មចូលទៅក្នុងទីផ្សារផ្សេងៗ ដូចជា ការពង្រីកពាណិជ្ជកម្មសំលៀកបំពាក់ជាមួយនឹងសហគមន៍អឺរ៉ុប ប្រទេសជប៉ុន និងកាណាដា ជាដើម ។ ពិពិធកម្មផលិតផលនាំចេញផ្សេងៗ ជាបន្ថែមលើពិពិធកម្មលើទីផ្សារ ក៏ជាដំណោះស្រាយរយៈពេលវែងមួយសំរាប់វិបត្តិនេះដែរ ។ ការទាក់ទាញជំនួយសំរាប់ពាណិជ្ជកម្ម អាចជួយឲ្យកម្ពុជាធ្វើហិរញ្ញប្បទានលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ បង្កើនលទ្ធភាពទាញយកចំណេញពីឱកាសរកបានទីផ្សារ ។ ហិរញ្ញប្បទានសំរាប់ពាណិជ្ជកម្មពីសំណាក់ធនាគារ ក៏សំខាន់ណាស់ដែរ ។ ឥណទានសំរាប់ការនាំចេញ អាចជួយច្រើនណាស់ដល់អ្នកនាំចេញនានា ដែលរងការប៉ះពាល់ខ្លាំងពីវិបត្តិ ។

មេរៀនមួយទៀត ដែលជាប់ទាក់ទងនឹងបញ្ហាខាងលើនេះដែរ គឺសមត្ថភាពប្រកួតប្រជែង ។ ទោះបីកម្ពុជាបានឈានឡើងមួយកំរិតហើយក្តី ក៏នៅតែស្ថិតក្នុងចំណោមប្រទេសដែលមានសមត្ថភាពប្រកួតប្រជែងទាបបំផុតនៅក្នុងតំបន់ដែរ។ រឿងនេះកើតចេញមួយផ្នែកអំពីបន្ទុកចំណាយខ្ពស់ក្នុងផលិតកម្ម និង ជំនួញ ។ ការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធ ការកែលំអគ្រឿងសំរបសំរួលពាណិជ្ជកម្ម និង ការកាត់បន្ថយចំណាយធ្វើអាជីវកម្មនៅក្នុងប្រទេស នឹងជួយបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ។

មេរៀនជាប់ទាក់ទងនឹងវិស័យធនាគារ ទាមទារដំណោះស្រាយរយៈពេលខ្លី និងរយៈពេលវែង សំរាប់បញ្ហាបង្កឡើងដោយវិបត្តិ ។ ការកាត់បន្ថយថែមទៀតនូវទុនបំរុងជាកាតព្វកិច្ច អាចជួយបន្ធូរបន្ថយបានភ្លាមៗនូវភាពតានតឹងក្នុងប្រព័ន្ធធនាគារ ព្រោះវានឹងផ្តល់សាច់ប្រាក់បន្ថែមឲ្យធនាគារ ។ ដំណោះស្រាយរយៈពេលវែង តំរូវឲ្យមានការពង្រឹងការពិនិត្យតាមដានផ្នែកធនាគារ (ឧ. ការពិនិត្យតាមដានពីចំងាយ និង ដល់កន្លែង) និង ការកសាងឧបករណ៍ខាងរូបិយវត្ថុសំរាប់ជួយសំរួលប្រតិបត្តិការអន្តរធនាគារ ។

មេរៀនសំខាន់ និងកាន់តែស៊ីជម្រៅមួយទៀត ពាក់ព័ន្ធនឹងតំរូវការលុបបំបាត់ចោលឧបសគ្គខាង រចនាសម្ព័ន្ធ ដែលរារាំងកំណើនមានមូលដ្ឋានធំទូលាយ ក្នុងនេះមានការដាក់អនុវត្តគោលនយោបាយ ជួយជំរុញកំណើនមានលក្ខណៈរាប់បញ្ចូល ដើម្បីឲ្យប្រជាជនកាន់តែច្រើនឡើងមានចំណែកទទួលបានផលចំណេញពីកំណើន ។ ក្នុងដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍន៍ ការដោះស្រាយឧបសគ្គដល់ការអភិវឌ្ឍន៍កសិកម្ម ដូចជា កង្វះវិនិយោគជាដើម ទំនងជាយុទ្ធសាស្ត្រ ដែលល្អជាងគេហើយ ។ ប៉ុន្តែក្នុងពេលជាមួយគ្នា ក៏ត្រូវធ្វើពិពិធកម្មសេដ្ឋកិច្ចទាំងមូលដែរ ។ ការរីកចំរើនដែលពឹងផ្អែកខ្លាំងលើវិស័យមានកំណើនខ្ពស់ទាំង៤ ធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅណាស់ ។ ដូច្នេះ ត្រូវតែមានបង្កើតវិស័យកំណើនផ្សេងៗទៀតក្រៅពីវិស័យកំណើនទាំង៤ ខាងលើ ដូចជា ត្រូវពង្រីកផលិតកម្មកម្មន្តសាលផ្សេងៗទៀត ក្រៅពីផ្នែកកាត់ដេរ ។ ជារៀងរាល់ឆ្នាំ មានចំណូលថ្មីទៅក្នុងកំលាំងពលកម្មប្រហែល ២៥០.០០០ ទៅ ៣០០.០០០នាក់ ។ ដូច្នេះ ដើម្បីមានកន្លែងសំរាប់អ្នកស្វែងរកការងារទាំងឡាយ កម្ពុជាត្រូវតែធ្វើពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន ។

**CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា ✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh, website: http://www.cdri.org.kh